**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ភាគីដាក់ឯកសារ:** សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

**ដាក់ជូន:** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Sep-2015, 14:37
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ:** **សាធារណៈ/Public**

**ឋានៈនៃចំណាត់ថ្នាក់ឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

**សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំការបំភ្លឺអំពីវិសាលភាពនៃការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការ**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**<u>ជនជាប់ចោទ៖</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីការពារក្តី៖</u>**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**<u>មេធាវីប្រចាំការ៖</u>**

ទូច វរល័ក្ស

Calvin SAUNDERS

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

Beini YE

## I. សេចក្តីផ្តើម

1. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមស្នើឱ្យមានការបំភ្លឺជាលាយលក្ខណ៍អក្សរតាមការចង្អុលបង្ហាញពីអង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងវិសាលភាពនៃការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការ[1]។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១០ ញឹប ហល់ (D22/3050) ត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីដោយការិយាល័យសហចៅក្រមស៊ើបអង្កេត[2] រួមជាមួយនឹងបុគ្គល ៤៩ នាក់ផ្សេងទៀតដោយផ្អែកលើមូលដ្ឋានថា គាត់បានទទួលទទួលរងព្យសនកម្មផ្ទាល់ខ្លួន *ជាក់ស្តែង* ដោយសារតែផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មនានា ដូចមានចែងនៅក្នុងកថាខណ្ឌ ៤៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ពាក់ព័ន្ធនឹងការដ្ឋានទំនប់ត្រពាំងថ្ម[3]។

3. ក្រុមមេធាវីការពារក្តី (ហៅជារួមថា "មេធាវីការពារក្តី") មិនបានដាក់បណ្តឹងសាទុក្ខណាមួយប្រឆាំងនឹងការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីរូបនេះឡើយ ទោះបីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនមកពីក្រុមតែមួយក៏ដោយ[4]។

4. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានស្នើឱ្យភាគីនានា ដាក់សម្ភារៈដើម្បីរៀបចំសវនាការដោយបានណែនាំថា ភ័ស្តុតាងដែលបានលើកឡើង ត្រូវកំណត់ប្រភេទថាជា

---

[1] ប្រតិចារឹក ឯកសារ **E1/336.1** (ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥) ទំព័រ ២៦។

[2] ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាននៅក្នុងខេត្តបន្ទាយមានជ័យ ឯកសារ **D416** ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១០ ទំព័រ ១១ *សូមមើលផងដែរ* ឯកសារ **D146.1** ឧបសម្ព័ន្ធ ២ ទំព័រ ២៦។

[3] ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្នុងខេត្តបន្ទាយមានជ័យ ឯកសារ **D416** ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ២២។

[4] *សូមមើលឧទាហរណ៍* សេចក្តីបង្គាប់ចំពោះសហមេធាវីការពារក្តី ខៀវ សំផន ឱ្យដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ **D416/8/2** ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១១។

អង្គហេតុដែលត្រូវបញ្ជាក់ដោយភ័ស្តុតាងនៅពេលជំនុំជម្រះ (ដូចបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[5]។

5. នៅថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ នៅពេលដាក់បញ្ជីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានធ្វើបច្ចុប្បន្នភាពនោះ សហមេធាវីនាំមុខ បានស្នើឲ្យ ញឹប ហល់ (ដែលនៅពេលពេលនោះមានរហស្សនាម TCCP-96) ផ្តល់សក្ខីកម្មលើអង្គហេតុដែលពាក់ព័ន្ធនឹងការដ្ឋានទំនប់ត្រពាំងថ្ម។ ភាគីនានា និងអង្គជំនុំជម្រះសាលាដំបូង ត្រូវបានជូនដំណឹងថា សក្ខីកម្មរបស់គាត់នឹងមានការជាប់ពាក់ព័ន្ធនឹងចំណុចខាងក្រោមក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖

> "[...] ២២. អត្ថិភាព និងរចនាសម្ព័ន្ធសហករណ៍ និងការដ្ឋាន ការដ្ឋានទំនប់ត្រពាំងថ្មដែលត្រូវចោទប្រកាន់ កថាខណ្ឌ ៣២៣-៣៣២, ៣៣៤-៣៣៥។
>
> ២៣. លក្ខខណ្ឌធ្វើការងារ និងរស់នៅ ដែលត្រូវចោទ (រួមទាំងការរៀបអាពាហ៍ពិពាហ៍ជាក្រុម) ក្នុងសហករណ៍ និងការដ្ឋាន កថាខណ្ឌ ៣៣៦-៣៤៥។ [...]"[6]

6. នៅក្នុងសារណាដែលមានភ្ជាប់មកជាមួយនូវបញ្ជីនេះជាឧបសម្ព័ន្ធ សហមេធាវីនាំមុខ បានអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្លួនបានស្នើសុំកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គឺជាអ្នកដែលថានឹង "ជួយជាដុំកំភួនដល់អង្គជំនុំជ្រះសាលាដំបូងក្នុងការស្វែងរកការពិត ដែលពាក់ព័ន្ធនឹងការចោទប្រកាន់នានាដែលត្រូវបានយកមកជំនុំជម្រះក្នុងសំណុំរឿង ០០២/២ ជាពិសេសក្នុងការបង្ហាញភ័ស្តុតាងដែលមានមូលដ្ឋានលើឧក្រិដ្ឋកម្ម និងក្នុងការជួយ

---

[5] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ឯកសារ **E9** ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ១ – បញ្ជីនៃអង្គហេតុដែលត្រូវបញ្ជាក់ដោយភ័ស្តុតាង ឯកសារ **E9.1** ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១។

[6] ឧបសម្ព័ន្ធ III–សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ (ដែលពុំបានស្វែងរកវិធានការការពារ) ឯកសារ **E305/7.1.3** ទំព័រ ៣០ លេខរៀង ៣៣ ត្រូវនឹងលេខរៀង ២៣ នៅក្នុងឧបសម្ព័ន្ធ ១ – បញ្ជីនៃអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាង ឯកសារ **E9.1** ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៤។

អង្គជំនុំជម្រះដើម្បីវាយតម្លៃពីស្ថានទម្ងន់នៃឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណី"[7]។

7. នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហាល់ (ដែលមានរហស្សនាម 2-TCCP-269 សម្រាប់សំណុំរឿង ០០២/២) ឱ្យមកបង្ហាញខ្លួននៅក្នុងសវនាការនៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥ ដើម្បីឆ្លើយសំណួរ[8]។

8. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥ ក្នុងអំឡុងពេលដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហាល់ (2-TCCP-269) កិច្ចពិភាក្សានោះ ត្រូវបានធ្វើឡើងទាក់ទងនឹងវិសាលភាពនៃការសួរដេញដោលលើរូបគាត់នៅក្នុងសវនាការ[9]។

9. នៅថ្ងៃដដែលនោះដែរ ការសាកសួរដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីថាតើដើមបណ្តឹងរដ្ឋប្បវេណីរូបនោះ បានសង្កេតឃើញមាន "អាពាហ៍ពិពាហ៍ណាមួយ" ដែរឬទេ ក្នុងអំឡុងពេលគាត់ស្ថិតនៅការដ្ឋានទំនប់ត្រពាំងថ្ម[10] ដែលចំណុចនេះធ្វើឱ្យមានការកត់សម្គាល់ភ្លាមៗមួយពីសំណាក់មេធាវីការពារក្តីរបស់ នួន ជា ថា ដើមបណ្តឹងរដ្ឋប្បវេណី អាច "ផ្តល់សក្ខីកម្មទាក់ទងទៅនឹងរបួសស្នាមដែលគាត់បានទទួល ពីការធ្វើការនៅទំនប់ត្រពាំងថ្មតែប៉ុណ្ណោះ"[11]។ ក្នុងការគាំទ្រដល់ការកត់សម្គាល់នេះ មេធាវីការពារក្តីរបស់ នួន ជា នៅពេលនោះបានដកស្រង់លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយកជា ដើមបណ្តឹងរដ្ឋប្បវេណី ពោលគឺ "ដើម្បីអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន ព្យសនកម្មត្រូវតែជា ក) រូបកាយ សម្ភារៈ ឬផ្លូវចិត្ត; ខ) ប៉ះពាល់ដោយផ្ទាល់ពីបទល្មើសនោះ ជាលក្ខណៈបុគ្គល និងមានឥទ្ធិពលរហូតមកដល់ពេលបច្ចុប្បន្ន"[12]។ មេធាវីការពារក្តីរបស់ នួន ជា បានកត់សម្គាល់ថា "គ្មានសំណួរណាមួយ [ដែលត្រូវបានចោទសួរក្នុង

---

[7] បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០ របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សំណុំរឿង ០០២/២ រួមទាំង ឧបសម្ព័ន្ធសម្ងាត់ ឯកសារ **E305/7** ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ កថាខណ្ឌ ៩។

[8] ដីកាកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ **E202/211** ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥។

[9] ប្រតិចារឹក ឯកសារ **E1/336.1** (ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥) ទំព័រ ២២-២៥។

[10] *ដូចឯកសារយោងខាងលើ* ទំព័រ ២០។

[11] *ដូចឯកសារយោងខាងលើ* ទំព័រ ២១។

[12] *ដូចជើងទំព័រខាងលើ*។

អំឡុងពេលសួរដេញដោល] រហូតមកដល់ពេលនេះ មានការជាប់ពាក់ព័ន្ធទៅនឹងការទទួលយករូបគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទំនប់នេះឡើយ"[13]។ មេធាវីការពារក្តីរបស់ នួន ជា បានចោទសួរថាហេតុអ្វីបានជាយើងមិនស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះក្នុងនាម "គ្រាន់តែជាសាក្សីធម្មតា" ទៅវិញ ហើយថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គួរផ្តោតលើចំណុចជាក់លាក់វិញ[14]។

10. ក្នុងអំឡុងពេលផ្តល់សក្ខីកម្មនៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥ មេធាវីការពារក្តីរបស់ ខៀវ សំផន បានបន្ថែមទៀតថា "អត់មានភាពខុសគ្នាទេ នៅពេលគាត់ធ្វើបែបនេះហ្នឹងរវាងសាក្សីធម្មតាម្នាក់ដែលផ្តល់សក្ខីកម្មទាក់ទងនឹងអង្គហេតុ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលឋានៈរបស់ពួកគេមានភាពខុសគ្នាស្រលះ"[15]។ មតិយោបល់ ជាពិសេសដែលពាក់ព័ន្ធនឹងបញ្ហាមួយ ខុសគ្នាពីចំណុចដែលបានលើកឡើងដោយមេធាវីការពារក្តីរបស់ នួន ជា ពោលគឺ "ចំណុចដែលមិនត្រូវបានលើកឡើងក្នុងពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនគួរត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះនេះក្នុងអំឡុងពេលសវនាការទាំងនេះឡើយ"[16]។ នៅក្នុងសវនាការពេលរសៀល មេធាវីការពារក្តីរបស់ ខៀវ សំផន បានបន្ថែមទៀតថា៖

> "[យើង] យើងមិនអាចនិយាយអំពីភាពអាចជឿជាក់របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅទីនេះបានទេ ពីព្រោះសហចៅក្រមស៊ើបអង្កេត មិនបានស្តាប់ចម្លើយរបស់គាត់ទេ។ អ៊ីចឹង ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនបានសួរអំពីបញ្ហាសារធាតុទៅលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ វាពិបាកណាស់។ ហើយយើងបានបញ្ជាក់ថា យើងមិនអាច--គេបញ្ជាក់ថា យើងមិនអាចសួរអំពីភាពជឿជាក់បានទេ ពីព្រោះគាត់ត្រូវបានទទួលជាដើមបណ្តឹងរដ្ឋប្បវេណីរួចទៅហើយ។ អ៊ីចឹង បើសិនជាមានសំណាង ហើយសំណាងនោះ សំណាងរួមបែបនេះ គឺខ្ញុំពិបាកយល់ដែរ"[17]។

---

[13] *ដូចជើងទំព័រខាងលើ។*

[14] *ដូចជើងទំព័រខាងលើ។*

[15] *ដូចឯកសារយោងខាងលើ* ទំព័រ ២៤។

[16] *ដូចជើងទំព័រខាងលើ។*

[17] *ដូចឯកសារយោងខាងលើ* ទំព័រ ៥៥។

11. ប្រការនេះបានជំរុញប្រធានអង្គជំនុំជម្រះ តម្រូវឱ្យសហមេធាវីនាំមុខដាក់សារណាជាលាយលក្ខណ៍អក្សរដើម្បីដោះស្រាយបញ្ហានេះជាផ្លូវការ[18]។

## III. ច្បាប់ជាធរមាន

### *ក. ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*

12. វិធាន ២៣ *ស្ទួន* (១) នៃវិធានផ្ទៃក្នុងចែងថា៖ "នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ"។

13. វិធាន ២៣ *ស្ទួន* (៣) នៃវិធានផ្ទៃក្នុងចែងថា៖ "សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសេសសល់ទាំងអស់ ដោយដីកាដោយឡែក។ ដីកានេះត្រូវបើកផ្លូវប្តឹងឧទ្ធរណ៍សង្ខេប ដោយភាគី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងក្នុងវិធាន ៧៧ *ស្ទួន*"។

14. វិធាន ២៣ *ស្ទួន* (៤) នៃវិធានផ្ទៃក្នុង បញ្ជាក់ពីលក្ខណៈនៃទម្រង់ និងខ្លឹមសាររបស់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយពន្យល់ថា៖ "[គ្រប់]ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ត្រូវមានព័ត៌មានគ្រប់គ្រាន់ដើម្បីអនុញ្ញាតឱ្យពិនិត្យបញ្ជាក់អំពីភាពសមស្របរបស់ពាក្យសុំតាំងខ្លួនទាំងនោះជាមួយនឹងវិធានផ្ទៃក្នុងនេះ។ ជាពិសេស ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវផ្តល់ព័ត៌មានលម្អិតអំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ និងភ្ជាប់មកជាមួយនូវភ័ស្តុតាងបញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬការបង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជនដែលត្រូវចោទប្រកាន់"។

15. វិធាន ៧៤(៣)(ឈ) នៃវិធានផ្ទៃចែងថា ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត "ដែលប្រកាសទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ វិធាន ៧៧ *ស្ទួន* នៃវិធានផ្ទៃក្នុង

---

[18] *ដូចឯកសារយោងខាងលើ* ទំព័រ ២៦។

ចែងថា បណ្ដឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៣(៣)(ឈ) ត្រូវតែពិចារណាឲ្យបានឆាប់រហ័ស។

### *ខ. សកម្មភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងពេលសវនាការ*

16. វិធាន ២៣ *ស្ទួន* (៣) នៃវិធានផ្ទៃក្នុងចែងថា៖ "[រាល់]ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ដែលត្រូវបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬដោយអង្គបុរេជំនុំជម្រះ តាមរយៈការប្ដឹងឧទ្ធរណ៍ឲ្យបានឆាប់ ដូចមានចែងនៅក្នុងវិធាននេះ ត្រូវបង្កើតជាក្រុមរួមបញ្ចូលគ្នាតែមួយ ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ អនុលោមតាមវិធាន ២៣(៥) នៃវិធានផ្ទៃក្នុង"[19]។

17. អង្គជំនុំជម្រះតុលាការកំពូលដែលបានទទួលស្គាល់ថា "សិទ្ធិចូលរួមយ៉ាងពេញលេញដែលដើមបណ្ដឹងរដ្ឋប្បវេណីផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ[កម្ពុជា] និងវិធានផ្ទៃក្នុងនៅមុនដំណាក់កាលជំនុំជម្រះ ក្នុងដំណាក់កាលជំនុំជម្រះ និងក្នុងដំណាក់កាលបណ្ដឹងសាទុក្ខ" បានបញ្ជាក់ថា ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានផ្ដល់សិទ្ធិឲ្យចូលរួមក្នុងនីតិវិធីខុសៗគ្នាទៅតាមមុខងារ និងការទទួលខុសត្រូវជាក់លាក់របស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធី [នៅ អ.វ.ត.ក][20]។

18. តាមវិធាន ១២ *ស្ទួនពីរ* (៥) នៃវិធានផ្ទៃក្នុង សហមេធាវីនាំមុខ មានភារកិច្ចតំណាងឲ្យផលប្រយោជន៍របស់ក្រុមដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយនៅក្នុងសវនាការក្នុងអំឡុងពេលនៃដំណាក់កាលជំនុំជម្រះ។ វិធាន ១២ *ស្ទួនពីរ* (៦) នៃវិធានផ្ទៃក្នុងចែងថា មុខងារ

---

[19] *សូមមើលផងដែរ* ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារ **E74** ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ២ ដែលបានបញ្ជាក់ថា៖ "[ដោយ]យោងទៅលើវិធាន ២៣(៣) ដែលត្រូវបានដាក់ចេញក្នុងខែ កុម្ភៈ ឆ្នាំ ២០១០ ជាផ្នែកមួយនៃការធ្វើវិសោធនកម្មលើកទី៥ នៃវិធានផ្ទៃក្នុង ចែងថា៖ "ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវរួមបញ្ចូលក្រុមតែមួយ ដែលផលប្រយោជន៍របស់ពួកគាត់ ត្រូវបានតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី"។ វិធាននេះកំណត់ធ្វើការបែងចែកខុសគ្នាអំពីការចូលរួមនៅមុនដំណាក់កាលជំនុំជម្រះ ដែលដើមបណ្ដឹងរដ្ឋប្បវេណីអាចចូលរួមជាលក្ខណៈបុគ្គលបាន។ វិធាននេះបានបង្កើតឲ្យមានប្រព័ន្ធនៃការចូលរួមរបស់ក្រុមដើមបណ្ដឹងរដ្ឋប្បវេណីតែមួយ ដែលនឹងត្រូវតំណាងដោយមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលសវនាការ ជាជាងការតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីជាលក្ខណៈបុគ្គល ដែលត្រូវបានតំណាងដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី"។

[20] សេចក្ដីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F10/2** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១១។

ទាំងនេះ ក្នុងចំណោមមុខងារផ្សេងៗ មានជាអាទិ៍ "ការស្ដាប់ចម្លើយកូនក្ដីរបស់ខ្លួន" ដោយមានការគាំទ្រដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធ។

19. លើសពីនេះទៀត ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ គឺអនុលោមតាមវិធាន ២១(១)(ក) និង(៤) វិធាន ៨៥ វិធាន ៨៧(៣) និង(៤) និងវិធាន ៩១(៣) នៃវិធានផ្ទៃក្នុង[21]។

20. ម្យ៉ាងវិញទៀត ពាក់ព័ន្ធទៅនឹងសកម្មភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទិននឹងការទាមទារសំណងរដ្ឋប្បវេណី វិធាន ២៣ *ស្ទួនបួន* (១) នៃវិធានផ្ទៃក្នុង ចែងថា អង្គជំនុំជម្រះ "អាចសម្រេចផ្ដល់ឱ្យតែសំណងផ្លូវចិត្ត និងជាសមូហភាពទៅដល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ" និងបានបញ្ជាក់ថា សំណងផ្លូវចិត្ត និងសមូហភាព គឺជាវិធានការដែល "ទទួលស្គាល់នូវការខូចខាតដែលដើមបណ្ដឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តិនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទដែលត្រូវបានផ្ដន្ទាទោស" និង "មិនត្រូវមានទម្រង់នៃសំណងជាប្រាក់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។ បន្ថែមពីលើនេះទៀត វិធាន ២១(១)(គ) តម្រូវឱ្យ អ.វ.ត.ក "ធានាថា ជនរងគ្រោះ ត្រូវទទួលបានការជូនព័ត៌មាន ហើយថា សិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្ដី"។

### *គ. ការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការ*

21. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូង បានអនុញ្ញាតឱ្យដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់ "សក្ខីកម្មលើអង្គហេតុនានា" ដែលកើតចេញពីបទពិសោធន៍របស់ខ្លួនក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យដោយមានការដាក់កម្រិតថា សក្ខីកម្មនេះ "ត្រូវបានកំណត់ក្នុងវិសាលភាព

[21] ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើសុំលេខ E67, E57, E56, E58, E23, E59, E20, E33, E71 និង E73 ក្រោយកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ឯកសារ **E74** ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ២-៣។ សូមមើលផងដែរ ញត្តិរបស់ អៀង សារី ស្នើសុំការណែនាំអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារ **E23** ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៨ ដែលមេធាវីការពារក្ដីរបស់ អៀង សារី បានស្វែងរកការដាក់កម្រិតកិច្ច អន្តរាគមន៍ពីដើមបណ្ដឹងរដ្ឋប្បវេណីចំពោះបញ្ហានានាដែលពាក់ព័ន្ធនឹងការចោទប្រកាន់ និងទាំងផលប្រយោជន៍នៃដើមបណ្ដឹងរដ្ឋប្បវេណី និងសម្រាប់គោលបំណងបង្ហាញពីព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

នៃសំណុំរឿង ០០២/០១ និងត្រូវមានការសួរតទល់គ្នា”[22]។ ដោយកត់សម្គាល់ថា វា “គ្រាន់តែជាការថ្លែងអំពីទុក្ខវេទនា ដែលមិនស្ថិតនៅក្រោមការកម្រិតដោយដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្ដីសម្រេចនានាដែលពាក់ព័ន្ធ” អង្គជំនុំជម្រះសាលាដំបូង បានតម្រូវឲ្យសហមេធាវីនាំមុខ “ធ្វើការធានាថា ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានស្នើឲ្យផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ពាក់ព័ន្ធតែទៅនឹងបញ្ហានានាក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ”[23]។

22. នៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានផ្ដល់ការណែនាំ និងគោលការណ៍ស្ដីពីដំណើរការ និងវិសាលភាពនៃការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីអង្គហេតុ និងក្នុងអំឡុងពេលសវនាការលើផលប៉ះពាល់នៃឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០០២/០២៖

> “៨. អង្គជំនុំជម្រះសូមរំលឹកដល់ភាគីអំពីការអនុវត្តរបស់ខ្លួន ពាក់ព័ន្ធនឹងភាពខុសគ្នារវាងសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីលើអង្គហេតុសម្រាប់ជំនុំជម្រះ និងសេចក្ដីទូទៅអំពីការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី (*សូមមើលឯកសារ E267/3* កថាខណ្ឌ ១៩)។ អនុលោមតាមការអនុវត្តនេះ អង្គជំនុំជម្រះនឹងតម្រូវឲ្យការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី កម្រិតត្រឹមតែអង្គហេតុទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ប៉ុណ្ណោះ រីឯការធ្វើសេចក្ដីថ្លែងទូទៅពីការឈឺចាប់ មិនតម្រូវឲ្យធ្វើការបែងចែកដាច់ពីគ្នារវាងព្យសនកម្មដែលកើតឡើងដោយសារអង្គហេតុដែលស្ថិតក្នុងវិសាលភាពសំណុំរឿង និងព្យសនកម្មទូទៅដែលបង្កឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ហើយការថ្លែងអំពីការឈឺចាប់នេះ គឺមិនត្រូវបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឡើយ។ ក្នុងករណីដែលសេចក្ដីថ្លែងពីការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី បានបង្ហើបនូវអង្គហេតុថ្មី ឬការចោទប្រកាន់ថ្មីប្រឆាំងនឹងជនជាប់ចោទ ដែលមិនទាន់បានពិភាក្សាដេញដោលនោះ អង្គជំនុំជម្រះអាចពិចារណា

---

[22] សេចក្ដីសម្រេចលើសំណើសុំកោះហៅសាជាថ្មីដើមបណ្ដឹងរដ្ឋប្បវេណី TCCP-187 និងសុំឲ្យពិនិត្យឡើងវិញលើបែបបទពាក់ព័ន្ធនឹងសក្ខីកម្មស្ដីពីការឈឺចាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសំណើ និងចម្លើយតបនានា ដែលពាក់ព័ន្ធនឹង (E240, E240/1, E250, E250/1, E267, E267/1 និង E267/2) ឯកសារ **E267/3** ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១៩។

[23] *ដូចឯកសារយោងខាងលើ* កថាខណ្ឌ ១៧។

ដើម្បីផលប្រយោជន៍យុត្តិធម៌ក្នុងការផ្តល់ឱកាសឲ្យភាគី តាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូប នោះ ពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងនោះបាន”[24]។

## V. ការពិភាក្សា

23. ទោះជាមេធាវីការក្តីរបស់ នួន ជា បានបញ្ជាក់ថា ពួកគេ “មិនមានការជំទាស់អ្វីនោះទេ ចំពោះសំណួរចុងក្រោយ ពីព្រោះថា វាច្បាស់ណាស់មានភាពពាក់ព័ន្ធទៅនឹងទំនប់”[25] ក្តី ក៏មេធាវីការពារក្តីរបស់ ខៀវ សំផន បានយល់ឃើញបញ្ហានេះថាជា “ការជំទាស់”[26] មួយ ហើយបានបញ្ចេញយោបល់បន្ថែមលើវិសាលភាពនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ទោះជាយ៉ាងណា ដើម្បីការដាក់សារណានេះ សហមេធាវីនាំមុខកត់សម្គាល់ឃើញថា យោបល់ដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តីនីមួយៗ មិនមែនជាការជំទាស់ ដែលអនុលោមតាមវិធានផ្ទៃក្នុង ៨៧(៣) នោះទេ ដោយសារថាមិនមានលក្ខណៈវិនិច្ឆ័យណាមួយដែលបានលើកឡើង ត្រូវបានលើកយោងនោះឡើយ។ ក្នុងបរិបទនេះ សហមេធាវីនាំមុខ សូមស្នើឲ្យមានការបញ្ជាក់ពីអង្គជំនុំជម្រះសាលាដំបូង ដែលបានកំណត់ត្រឹមតែបញ្ហាដែលបានលើកឡើងដូចជាបានណែនាំជាទូទៅដោយប្រធានជំនុំជម្រះ។

24. លើសពីនេះទៀត សហមេធាវីនាំមុខ សូមធ្វើការបង្ហាញពីបញ្ហានានាដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី ខណៈពេលដែលក្រុមនីមួយៗ បានលើកយោងទៅលើបទប្បញ្ញត្តិផ្សេងៗគ្នា ក្នុងបទបញ្ជាផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក។

25. ដូចបានបញ្ជាក់ម្តងហើយម្តងទៀតដោយសហមេធាវីនាំមុខក្នុងការដាក់ឯកសារនាពេលកន្លងមករបស់ខ្លួន ការគាំទ្រដល់ការ *កាត់សេចក្តី* (ដែលផ្ទុយទៅនឹង “ការិយាល័យសហព្រះរាជអាជ្ញា”) មានមូលដ្ឋានលើលទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី

---

[24] ព័ត៌មានអំពី (១) សវនាការលើការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ឯកសារ **E315/1** ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៨។

[25] ប្រតិចារឹក ឯកសារ **E1/336.1** (នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥) ទំព័រ ២១។

[26] *ដូចឯកសារយោងខាងលើ* ទំព័រ ២៣៖ “ការជំទាស់របស់លោក Victor Koppe កើតមានឡើងនៅពេលដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសួរគាត់អំពីរឿងរ៉ាវដែលគាត់មិនបាននិយាយនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី”។

ព្រហ្មទណ្ឌ តាមរយៈការផ្តល់សក្ខីកម្មអំពីអង្គហេតុដែលពួកគេបានដឹង។ សហមេធាវីនាំមុខ នាំយកឯកសារយោងអំពីសារណាមុនៗរបស់ខ្លួនលើទិដ្ឋភាពនេះ[27]។ មានការបន្ថែមថា គោលការណ៍នាំណែដែលស្ថិតនៅពីក្រោយសវនការស្តាប់ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺថា វាចូលរួមចំណែកចំពោះការស្វែងរកការពិត[28] ដូចមានការបញ្ជាក់ដោយប្រធានអង្គជំនុំជម្រះ[29]។

26. ចាប់ពីដំបូងមកម្លេះ សហមេធាវីនាំមុខបន្ថែមថា នៅឯការជំនុំជម្រះក្តី ដើមបណ្តឹងរដ្ឋប្បវេណីចូលរួមតាមរយៈក្រុមដើមបណ្តឹងរដ្ឋប្បវេណីដែលតំណាងដោយសហមេធាវីនាំមុខ ដោយមានការគាំទ្រពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី[30] ប្រឆាំងទៅនឹងអ្នកទាំងឡាយណាដែលទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ដោយសារតែជាភាគីម្នាក់នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលជាផ្នែកមួយនៃក្រុមដើមបណ្តឹងរដ្ឋប្បវេណីនោះ[31] ពួកគេមិនផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីនោះឡើយ[32]។ ដើមបណ្តឹងរដ្ឋប្បវេណីរក្សាសមភាពក្នុងឋានៈផ្លូវច្បាប់របស់ពួកគេជាមួយជនជាប់ចោទ ឬជនត្រូវចោទ ហើយ *មិនមែន* ជាសាក្សីម្នាក់នោះទេ។ ការណ៍នេះគឺស្របតាមវិធានផ្ទៃក្នុង[33] ច្បាប់របស់កម្ពុជា[34] និងច្បាប់របស់ប្រទេសបារាំង[35]។

---

[27] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់មេធាវីការពារក្តីរបស់ នួន ជា ពាក់ព័ន្ធនឹងការអនុវត្តមួយចំនួនដែលត្រូវមាន នៅពេលសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ **E336/1** នៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ២២-២៦។

[28] វិធាន ៩១(៣) នៃវិធានផ្ទៃក្នុង។

[29] ប្រតិចារឹក ឯកសារ **E1/336.1** (នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥) ទំព័រ ៣៥។

[30] វិធាន ២៣(៣) នៃវិធានផ្ទៃក្នុង។

[31] *សូមមើលបន្ថែម* វិធានផ្ទៃក្នុង ទំព័រ ៨០ "ដើមបណ្តឹងរដ្ឋប្បវេណី" ទំព័រ ៨១ "ភាគី"។

[32] វិធាន ២៣(៤) នៃវិធានផ្ទៃក្នុង។

[33] វិធាន ២៣ នៃវិធានផ្ទៃក្នុងចែងថា៖ "ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានគេសាកសួរដូចសាក្សីធម្មតាក្នុងរឿងក្តីតែមួយនេះបានទេ ហើយស្របតាមវិធាន ៦២ ដែលទាក់ទងទៅនឹងដីការចាត់ឲ្យស៊ើបសួរជំនួស អាចត្រូវបានគេស្តាប់ចម្លើយតែប៉ុណ្ណោះ ដោយស្ថិតក្រោមលក្ខខណ្ឌដូចគ្នាទៅនឹងជនត្រូវចោទ ឬជនជាប់ចោទដែរ"។ *សូមមើលផងដែរ* វិធាន ២៤(៤) នៃវិធានផ្ទៃក្នុង ដែលចែងថា សមាជិកគ្រួសារជិតស្និទ្ធរបស់ជនត្រូវចោទ ជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី មិនផ្តល់សក្ខីកម្មស្ថិតក្រោមសម្បថនោះឡើយ។

[34] មាត្រា ៣១២ នៃក្រមនីតិព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ "ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវគេស្តាប់ចម្លើយក្នុងឋានៈជាសាក្សីបានទេ"។

### ក. *សេចក្តីសង្កេតដោយមេធាវីការពារក្តីរបស់ នួន ជា*

27. សហមេធាវីនាំមុខលើកឡើងថា វិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក មានន័យច្បាស់លាស់ចំពោះបញ្ហាផ្សេងគ្នាចំនួនបីដែលលើកឡើងដោយមេធាវីការពារក្តីរបស់ នួន ជា ពោលគឺ (១) ភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី (២) វិសាលភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ និង (៣) ភាពខុសគ្នារវាងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី។

28. សហមេធាវីនាំមុខលើកឡើងថា មិនមានការរារាំងណាមួយនោះទេទៅលើដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មអំពីអង្គហេតុដែលត្រូវវិនិច្ឆ័យ ដើម្បីកំណត់ការផ្តល់សក្ខីកម្មនោះត្រូវធ្វើឡើងត្រឹម "របួសស្នាមដែលគាត់ទទួលបានពីការធ្វើការនៅទំនប់ត្រពាំងថ្មប៉ុណ្ណោះ" ដូចដែលបានលើកឡើងដោយមេធាវីការពារក្តីរបស់ នួន ជា[36]។ លើសពីនេះទៀត សហមេធាវីនាំមុខ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមិនមានកាតព្វកិច្ច ដែលត្រូវតែ "ផ្តោតលើចំណុចជាក់លាក់" នោះទេ បើទោះជាមានការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីអំពីអង្គហេតុនានានៅក្នុងពេលជំនុំជម្រះក្តី[37]។

29. ដោយពឹងផ្អែកលើយុត្តិសាស្ត្ររបស់ អ.វ.ត.ក និងការដាក់ឯកសារដែលពាក់ព័ន្ធក្នុងអំឡុងពេលដែលភាគីនានាបានស្នើដាក់បញ្ចូលសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីផ្តល់សក្ខីកម្មនោះ ច្បាស់ណាស់ថា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មលើអង្គហេតុដែលត្រូវវិនិច្ឆ័យ អាចធ្វើដូច្នេះបាន ដរាបណាអង្គហេតុទាំងនោះស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ គោរពតាមសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី និងអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងវិធាន ៨៥ និង ៨៧ នៃវិធានផ្ទៃក្នុង។

30. ក្នុងសំណុំរឿង ០០២/០១ ស្របតាមឯកសារលេខ E267/3 ដោយលើកលែងនូវសេចក្តីថ្លែងទូទៅរបស់ពួកគេអំពីការឈឺចាប់ ចំណុចរិតត្បិតលើដើមបណ្តឹងរដ្ឋប្បវេណី ដែលផ្តល់សក្ខីកម្ម

---

[35] ស្ថិតក្រោមច្បាប់បារាំង ការក្លាយខ្លួនជាភាគីមួយនៃកិច្ចដំណើរការនីតិវិធីផង និងសាក្សីផង មិនអាចទៅរួចនោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ នៅពេលដែលគាត់ចូលរួមជាដើមបណ្តឹង គាត់មិនអាចត្រូវបានគេស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនោះឡើយ។ *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង មាត្រា ៤២២។

[36] ប្រតិចារឹក ឯកសារ **E1/336.1** (ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥) ទំព័រ ២១។

[37] *ដូចខាងលើ*។

នៅចំពោះមុខអង្គជំនុំជម្រះគឺថា ការផ្តល់សក្ខីកម្មរបស់ពួកគេ ត្រូវតែពាក់ព័ន្ធទៅនឹង "បញ្ហានានាក្នុងសំណុំរឿង ០០២/០១"[38]។ មិនមានកាតព្វកិច្ចច្បាស់លាស់ ឬជាក់លាក់ ដែលបានដាក់លើដើមបណ្តឹងរដ្ឋប្បវេណី មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឬសហមេធាវីនាំមុខ ដើម្បីរឹតបន្តឹងលើការសួរដេញដោលរបស់ពួកគេចំពោះតែបញ្ហានានា ដែលជះឥទ្ធិពលដល់ភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី ព្យសនកម្មជាក់លាក់ដែលកើតឡើង និងដែលមានចែងក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ និង/ឬ ការចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលលើកឡើងក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេនោះទេ។ ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់យ៉ាងច្បាស់នូវវិសាលភាពនៃការផ្តល់សក្ខីកម្មដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី "ភាពខុសគ្នារវាងសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីលើអង្គហេតុសម្រាប់ជំនុំជម្រះ និងសេចក្តីថ្លែងទូទៅអំពីការឈឺចាប់" ដែលតម្រូវឲ្យមានការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី កម្រឹតត្រឹមតែ "អង្គហេតុទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ប៉ុណ្ណោះ"[39]។

31. ក្នុងអំឡុងកាត់សេចក្តីជាក់លាក់នេះ សហមេធាវីនាំមុខបានបញ្ជាក់ក្នុងតុលាការថា ដើមបណ្តឹងរដ្ឋប្បវេណី "មកផ្តល់សក្ខីកម្មនេះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលតំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលបានដាក់ពាក្យសុំចូលរួមនៅក្នុងសំណុំរឿងនេះ" និងថាដើមបណ្តឹងរដ្ឋប្បវេណី "និយាយពីអ្វីដែលគាត់បានមើលឃើញ គាត់ជួបប្រទះផ្ទាល់នៅក្នុង -- ពាក់ព័ន្ធនឹងអង្គហេតុដែលជាវិសាលភាពនៃសវនាការយើងនេះ"[40]។ ប្រតិចារឹកនេះ បញ្ជាក់បន្ថែមថា៖ "តាំងការចាប់ផ្តើមនៃសវនាការ ០០២/០១ រហូតដល់ ០០២/០២ នេះទៀត រហូតទៅដល់បើយើងនិយាយរហូតទៅដល់តាំងសំណុំរឿង០០១ករណីឌុច ក៏ដូចគ្នាដែរ គឺដើមបណ្តឹងរដ្ឋប្បវេណីអាចនិយាយពីអង្គហេតុ ដែលមិនពាក់ព័ន្ធគាត់ផ្ទាល់ ក៏ប៉ុន្តែស្ថិតនៅក្នុងវិសាលភាពនៃ

---

[38] សេចក្តីសម្រេចលើសំណើសុំកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឲ្យពិនិត្យឡើងវិញលើបែបបទពាក់ព័ន្ធនឹងសក្ខីកម្មស្តីពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើ និងចម្លើយតបនានាដែលពាក់ព័ន្ធ (E240, E240/1, E250, E250/1, E267, E267/1 និង E267/2) ឯកសារ **E267/3** នៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១៧។

[39] ព័ត៌មានអំពី (១) សវនាការលើការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ឯកសារ **E315/1** នៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៨។

[40] ប្រតិចារឹក ឯកសារ **E1/336.1** (ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥) ទំព័រ ២២-២៣។

សវនាការផងដែរ”[41]។ ជាពិសេស សហមេធាវីនាំមុខលើកឡើងថា ការសួរដេញដោលរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើអង្គហេតុនានា ដែលពាក់ព័ន្ធនឹងការចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការរៀបការដោយបង្ខំ ដែលអាចកើតមាននៅការដ្ឋានអាងត្រពាំងថ្ម ដែលទាំងពីរនេះស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ នោះ គឺមានលក្ខណៈ ស្របគ្នាទៅនឹងយុត្តិសាស្ត្ររបស់ អ.វ.ត.ក។

32. សហមេធាវីនាំមុខចាត់ទុកការសង្កេតបញ្ចប់សេចក្តីរបស់មេធាវីការពារក្តី នួន ជា ថា ដើមបណ្តឹងរដ្ឋប្បវេណី គួរតែផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីម្នាក់ ដែលការយល់ដូច្នេះគឺច្រានចោលទាំងស្រុងនូវយុត្តិសាស្ត្រ និងការអនុវត្តដែលត្រូវបានបង្កើតឡើងរបស់ អ.វ.ត.ក និងក្នុងពេលដែលមិនមានការជំទាស់ផ្លូវការ ទៅនឹងភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអំឡុងពេលសមស្រប ដែលជាបញ្ហាមួយចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងការជំនុំជម្រះក្តី។

33. លើសពីនេះ នៅពេលមានការស្នើដាក់បញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធ សហមេធាវីនាំមុខបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានាថា ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នឹងបង្ហាញពី “លក្ខខណ្ឌការងារ និងរស់នៅ ដែលត្រូវចោទ (រួមទាំងការៀបអាពាហ៍ពិពាហ៍ជាក្រុម) ក្នុងសហករណ៍ និងការដ្ឋាន” ដូចបានលើកឡើងក្នុងកថាខណ្ឌ ៣៣៦-៣៤៥ នៃដីកាដំណោះស្រាយ[42]។

34. ហេតុដូច្នេះ សហមេធាវីនាំមុខសូមបញ្ជាក់ថា មិនមានព្យសនកម្មដែលកើតមានឡើងចំពោះភាគីនានាដោយសារតែការសាកសួររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការរៀបការដោយបង្ខំនោះទេ។ ដោយគ្មានបង្ហាញព្យាសនកម្មជាក់លាក់ដែលកើតមានឡើងចំពោះសហជនជាប់ចោទដោយសារការអនុវត្ត ដែលត្រូវបានធ្វើឡើងជាទូទៅ ឬដោយសារការកាត់សេចក្តីជាក់លាក់ ដើម្បីធ្វើសេចក្តីសង្កេតដែលបង្ហាញពីភាពមិនសមរម្យក្នុងនីតិវិធីនេះ ត្រឹមតែនាំឲ្យឈានទៅរកការពន្យាពេលកិច្ចដំណើរការនីតិវិធីនេះប៉ុណ្ណោះ។

---

[41] *ដូចខាងលើ។*

[42] ឧបសម្ព័ន្ធ III៖ សេចក្តីសង្ខេបដែលបានធ្វើបច្ចុប្បន្នភាពអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ (ដែលពុំបានស្វែងរកវិធានការការពារ) ឯកសារ **E305/7.1.3** ទំព័រ ៣០ លេខរៀង ៣៣។

## ខ. សេចក្តីសង្កេតលើការលើកឡើងរបស់មេធាវីការពារក្តីរបស់ ខៀវ សំផន

35. ដូចគ្នានឹងមេធាវីការពារក្តីរបស់ ខៀវ សំផន ដែរ សហមេធាវីនាំមុខក៏បានលើកឡើងនាពេលកន្លងមកផងដែរដោយបញ្ជាក់ពីភាពខុសគ្នារវាងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី[43] ស្របតាមវិធានផ្ទៃក្នុង[44] ច្បាប់កម្ពុជា[45] និងច្បាប់របស់ប្រទេសបារាំង[46] ដែលចែងថា ការក្លាយខ្លួនជាភាគីមួយនៃកិច្ចដំណើរការនីតិវិធីផង និងសាក្សីផង មិនអាចទៅរួចនោះទេ[47]។ ដើម្បីបញ្ជាក់សាជាថ្មី ក្នុងបរិបទនៃដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់ភស្តុតាងតាមរយៈ "ការផ្តល់សក្ខីកម្ម" ក្នុងតុលាការ មានតែការហាមឃាត់ដាក់លាក់តែមួយគត់ដែលពួកគេអាច *មិនធ្លាប់* ត្រូវបានគេស្តាប់ចម្លើយក្នុងនាមជាសាក្សី ឬសាកសួរក្នុងនាមសាក្សីសាមញ្ញម្នាក់ ប៉ុន្តែអាចត្រឹមតែត្រូវបានសម្ភាសស្ថិតក្រោមលក្ខខណ្ឌ *ដូចគ្នា* ទៅនឹងជនត្រូវចោទ ឬជនជាប់ចោទ។

36. ទោះជាយ៉ាងណា ការលើកឡើងរបស់មេធាវីការពារក្តីរបស់ ខៀវ សំផន ដែលថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចផ្តល់សក្ខីកម្មទាក់ទងទៅនឹង "ចំណុចដែលមិនបានលើកឡើងក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី [...] នៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលសវនការទាំងនេះ" មិនត្រឹមត្រូវនោះទេ បើតាមទ្រឹស្តី និងអនុវត្តជាក់ស្តែង។

---

[43] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់មេធាវីការពារក្តីរបស់ នួន ជា ពាក់ព័ន្ធនឹងការអនុវត្តមួយចំនួនដែលត្រូវមាន នៅពេលសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ **E336/1** នៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ កថាខណ្ឌ ២៤ *ដោយដកស្រង់* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១២ ស្របទៅនឹងវិធាន ២៣ នៃវិធានផ្ទៃក្នុង។

[44] វិធាន ២៣ នៃវិធានផ្ទៃក្នុង ចែងថា៖ "ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានគេសាកសួរដូចសាក្សីធម្មតាក្នុងរឿងក្តីតែមួយនេះបានទេ ហើយស្របតាមវិធាន ៦២ ដែលទាក់ទងទៅនឹងដីការចាត់ឱ្យស៊ើបសួរជំនួស អាចត្រូវបានគេស្តាប់ចម្លើយតែប៉ុណ្ណោះដោយស្ថិតក្រោមលក្ខខណ្ឌដូចគ្នាទៅនឹងជនត្រូវចោទ ឬជនជាប់ចោទដែរ"។ *សូមមើលផងដែរ* វិធាន ២៤(៤) នៃវិធានផ្ទៃក្នុងដែលចែងថា សមាជិកគ្រួសារជិតស្និទ្ធរបស់ជនត្រូវចោទ ជនជាប់ចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី មិនផ្តល់សក្ខីកម្មស្ថិតក្រោមសម្បថនោះឡើយ។

[45] មាត្រា ៣១២ នៃក្រមនីតិព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា៖ "ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវគេស្តាប់ចម្លើយក្នុងឋានៈជាសាក្សីបានទេ"។

[46] ស្ថិតក្រោមច្បាប់បារាំង ការក្លាយខ្លួនជាភាគីមួយនៃកិច្ចដំណើរការនីតិវិធីផង និងសាក្សីផង មិនអាចទៅរួចនោះទេ។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ នៅពេលដែលគាត់ចូលរួមជាដើមបណ្តឹង គាត់មិនអាចត្រូវបានគេស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនោះឡើយ។ *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង មាត្រា ៤២២។

[47] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង មាត្រា ៤២២។

37. សហមេធាវីនាំមុខលើកឡើងថា ស្ថិតក្រោមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ភ័ស្តុតាងគ្រប់ប្រភេទគឺអាចទទួលយកធ្វើជាបញ្ហាគោលការណ៍មួយក្នុងអំឡុងពេលការជំនុំជម្រះទោសឧក្រិដ្ឋកម្មមួយ ហើយគ្មានវិធានណាមួយរឹតបន្តឹងបញ្ហានេះដែលដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានចៅក្រមស្តាប់ចម្លើយនោះទេ[48]។ ចៅក្រមក្នុងតុលាការកម្ពុជាមានកាតព្វកិច្ច "ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញតាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍"[49]។ ដូចគ្នានេះដែរ ច្បាប់របស់ប្រទេសបារាំងមិនបានដាក់ការរឹតបន្តឹងណាមួយនោះទេទៅលើវិសាលភាព ឬខ្លឹមសារនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលជំនុំជម្រះក្តី ពោលគឺចម្លើយទាំងនេះអាចរក្សាទុកសម្រាប់ការចោទប្រកាន់ដែលត្រូវបានធ្វើឡើងក្នុងសំណុំរឿងនេះ និង/ឬផលប៉ះពាល់នៃឧក្រិដ្ឋកម្ម[50]។

38. ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់វិធីសាស្ត្រកាន់តែតឹងរឹងមួយជាប្រយោជន៍ដល់សិទ្ធិរបស់ជនជាប់ចោទ ដោយកំណត់ការផ្តល់សក្ខីកម្មអំពីអង្គហេតុនានាចំពោះអង្គហេតុដែលពាក់ព័ន្ធទៅនឹងការចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ និងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធ[51]។

---

[48] មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា៖ "លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី។ តុលាការថ្លឹងថ្លែងដោយឥស្សរចិត្តអំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន។ តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ។

[49] មាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា៖ "ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញតាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍"។

[50] មាត្រា ៣៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង ចែងថា៖ "នៅពេលការស៊ើបអង្កេតដែលត្រូវបានធ្វើឡើងក្នុងអំឡុងសវនាការ ត្រូវបានបញ្ចប់ ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីរបស់គាត់ត្រូវបានគេស្តាប់ចម្លើយ។ ព្រះរាជអាជ្ញាសាធារណៈដាក់ជូនសេចក្តីសន្និដ្ឋានរបស់គាត់។ ជនជាប់ចោទ និងមេធាវីរបស់គាត់បង្ហាញទឡ្ហីករណ៍ការពាររបស់ពួកគេ។ ដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញាសាធារណៈអាចឆ្លើយតប ប៉ុន្តែជនជាប់ចោទ និងមេធាវីរបស់គាត់នឹងតែងតែមានសិទ្ធិនិយាយរហូតដល់ទីបញ្ចប់"។ ការណ៍នេះមិនដូចទៅនឹងសាក្សីនោះឡើយដែលត្រូវបានស្នើឲ្យផ្តល់សក្ខីកម្មតែ "ទាក់ទងនឹងបញ្ហានានាដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ឬទាក់ទងនឹងបុគ្គលភាព ឬសីលធម៌របស់គាត់តែប៉ុណ្ណោះ"។ (មាត្រា ៣៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង)។

[51] *ដូចខាងលើ* កថាខណ្ឌ ១៧។

ទាក់ទងនឹងសេចក្តីថ្លែងទូទៅអំពីការឈឺចាប់ អង្គជំនុំជម្រះមិនបានតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណី "ធ្វើការបែងចែកដាច់ពីគ្នារវាងព្យសនកម្មដែលកើតឡើងដោយសារអង្គហេតុ ដែលស្ថិតក្នុងវិសាលភាពសំណុំរឿង និងព្យសនកម្មទូទៅដែលបង្កឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ហើយការថ្លែងអំពីការឈឺចាប់នេះ គឺមិនត្រូវបានបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឡើយ"[52]។

39. សហមេធាវីនាំមុខលើកឡើងថា បទដ្ឋានបច្ចុប្បន្នដូចដែលកំណត់ និងលម្អិតដោយអង្គការជំនុំជម្រះសាលាដំបូងក្នុងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរចំពោះវិសាលភាពនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើអង្គហេតុ ហើយការថ្លែងអំពីការឈឺចាប់ ឆ្លើយតបទៅតាមលក្ខខណ្ឌតម្រូវនៃសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយមិនបង្កអន្តរាយដល់សហជនជាប់ចោទឡើយ។

40. ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងបញ្ហាប្រឈមទៅនឹង "ភាពដែលអាចជឿបាន" របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយ "សហចៅក្រមស៊ើបអង្កេតមិនបានសួរឲ្យបានល្អិតល្អន់"[53] សហមេធាវីនាំមុខលើកឡើងថា ក្រុមមេធាវីការពារក្តីមិនត្រូវបានហាមឃាត់មិនឲ្យសួរដេញដោលលើខ្លឹមសារនៃសេចក្តីថ្លែងការណ៍នាពេលកន្លងមករបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ថាតើខ្លឹមសារនោះមាននៅក្នុងបែបបទនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កំណត់ហេតុនៃការស្តាប់ចម្លើយ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬសេចក្តីថ្លែងការណ៍ដែលធ្វើឡើងដោយអង្គភាពនានាស្ថិតនៅក្រៅ អ.វ.ត.ក។

41. លើសពីនេះទៀត សហមេធាវីនាំមុខកត់សម្គាល់ថា កំណត់ត្រាពីអង្គជំនុំជម្រះសាលាដំបូងបានរឹតត្បិតតម្លៃភ័ស្តុតាងទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[54]។ មេធាវីការពារក្តីមាន

---

[52] ព័ត៌មានអំពី (១) សវនាការលើការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ឯកសារ **E315/1** នៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៨។

[53] ប្រតិចារឹក ឯកសារ **E1/336.1** (ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥) ទំព័រ ៥៥។

[54] គោលការណ៍ណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីក្នុងសំណុំរឿង ០០៣ និង ០០៤ នៅក្នុងសំណុំរឿង ០០២/០២ ឯកសារ **E319/14/2** នៅថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ៤ ដែលចែងថា៖ "អង្គជំនុំជម្រះសូមរំលឹកដល់ភាគីថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានតម្លៃជាភស្តុតាងតិចជាងកំណត់

សេរីភាពពេញលេញក្នុងការប្រើប្រាស់ពាក្យសុំទាំងនោះ ក្នុងអំឡុងពេលសួរដេញដោលរបស់ពួកគេ ដើម្បីតបតរ និងបញ្ជាក់ឲ្យច្បាប់ពីអង្គហេតុដែលត្រូវបានផ្តល់នៅក្នុងតុលាការ ពោលគឺជាបុព្វសិទ្ធិមួយដែលពួកគេបានអនុវត្តជាញឹកញាប់សូម្បីតែទាក់ទងទៅនឹងកាលៈទេសៈនានាដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលក្តី[55]។ ហេតុដូច្នេះ សហមេធាវីនាំមុខសន្និដ្ឋានថា មេធាវីការពារក្តីមិនបានបង្កឲ្យមានព្យសនកម្មលើការរៀបរាប់ ដើម្បីគាំទ្រដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការពិនិត្យមើលឡើងវិញនូវការអនុវត្តដែលត្រូវបានបង្កើតឡើងពាក់ព័ន្ធនឹងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការ។

42. ផ្ទុយទៅនឹងការយល់ឃើញរបស់មេធាវីការពារក្តី ការអនុវត្តនាពេលបច្ចុប្បន្នមិនបង្កផលប៉ះពាល់ដល់មេធាវីការពារក្តីរបស់សហជនជាប់ចោទនោះទេ។ ជាការពិត ពាក់ព័ន្ធទៅនឹងការរឹតបន្តឹងផ្នែកច្បាប់ទៅលើលទ្ធភាពរបស់សហមេធាវីនាំមុខ ក្នុងការដាក់ជូនព័ត៌មានបន្ថែម ដើម្បីធ្វើជា "ភ័ស្តុតាងថ្មី" ដែលមិនស្ថិតនៅក្នុងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទនោះ[56] ការអនុវត្តនា

---

ហេតុនៃការស្តាប់ចម្លើយ ហើយអង្គជំនុំជម្រះក៏បានសំអាងលើតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមលើសំណុំរឿង ០០២/០១ សម្រាប់គោលបំណងដើម្បីផ្ទៀងផ្ទាត់ភស្តុតាងផ្សេងទៀតតែប៉ុណ្ណោះទេ។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំរបស់ព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E96/7** នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៩។ *សូមមើលបន្ថែម* សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារទាំងឡាយដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ឯកសារ **E305/17** នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ២៥។ សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត ឯកសារ **E185/1** កថាខណ្ឌ ១៣។

[55] *សូមមើលឧទាហរណ៍* ឯកសារ **E1/252.1** ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ១៤-១៥ (មេធាវីការពារក្តីរបស់ នួន ជា) ទំព័រ២៤-២៥ (មេធាវីការពារក្តី ខៀវ សំផន) ឯកសារ **E1/287.1** ចុះថ្ងៃទី ២ ខែ មេសា ឆ្នា ២០១៥ ទំព័រ ២១-២៣ (មេធាវីការពារក្តីរបស់ ខៀវ សំផន)។

[56] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧(៤) ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី D22/2500 ដោយភ្ជាប់ជាមួយឧបសម្ព័ន្ធ ក សម្ងាត់ ឯកសារ **E344/1** នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៥ កថាខណ្ឌ ៤-៥ ដែលចែងថា៖ "៤. អង្គជំនុំជម្រះសាលាដំបូងសង្កេតឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណី *D22/2500* ត្រូវបានដាក់នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ មុនពេលចាប់ផ្តើមជំនុំជម្រះ។ បើទោះជាពាក្យសុំនេះមិនមែនជាភស្តុតាងដែលត្រូវវិនិច្ឆ័យស្តីអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទក៏ដោយ ក៏ពាក្យសុំនេះពិតជាបានបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានធ្វើការនៅក្នុងកងពិសេសក្នុងស្រុកត្រាំកក់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះយល់ឃើញថា ព័ត៌មានពាក់ព័ន្ធទៅនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទនេះ គួរតែត្រូវបានរកឃើញនា

ពេលបច្ចុប្បន្ន អនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកអង្គហេតុ និងព័ត៌មានទាំងអស់ ដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ពីដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីពន្លឿនការស្វែងរកការពិត ខណៈពេលជាមួយគ្នានោះដែរ អនុញ្ញាតឲ្យក្រុមមេធាវីការពារក្ដីជំទាស់ទៅនឹងព័ត៌មានបែបនេះ ដែលស្ថិតក្នុងក្របខ័ណ្ឌដែលបានរៀបរាប់លម្អិតខាងលើ។

## IV. សំណើ

**ហេតុដូចនេះ** សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសូមគោរពថា អង្គជំនុំជម្រះសាលាដំបូង៖

(១) **តម្កល់** សេចក្ដីណែនាំដែលមានចែងក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង (E315/1) ទាក់ទងនឹងវិសាលភាពនៃការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអំពីអង្គហេតុ និងទាំងព្យសនកម្មដែលកើតឡើង។

(២) **តម្កល់ថា** ការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីអំពីអង្គហេតុដែលត្រូវវិនិច្ឆ័យ មិនត្រូវបានកំណត់ត្រឹមចំពោះហេតុផលនៃភាពអាចទទួលយកបានរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធ ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ។

(៣) **តម្កល់ថា** ការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីអំពីអង្គហេតុដែលត្រូវវិនិច្ឆ័យ មិនត្រូវបានរឹតត្បិតត្រឹមតែព្យសនកម្មដែលបានកើតឡើង ដោយដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនឯងផ្ទាល់ ដោយសារអំពើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និង

(៤) **តម្កល់ថា** ដើមបណ្ដឹងរដ្ឋប្បវេណីដែលផ្ដល់សក្ខីកម្មអំពីអង្គហេតុដែលត្រូវវិនិច្ឆ័យ មានសិទ្ធិធ្វើដូច្នោះ លើកលែងតែអង្គហេតុដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០២ ដូចដែលបានរឹតត្បិត ដោយឯកសារ E301/9/1.1។

---

ពេលក្រោយមក បន្ទាប់ពីបានខិតខំស្វែងរកដោយសមស្រប តាមរយៈការសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សហមេធាវីនាំមុខមានកាតព្វកិច្ចស្នើសុំឲ្យទទួលយកភស្តុតាងនេះឲ្យបានទាន់ពេលវេលា យ៉ាងហោចណាស់នៅមុនការចាប់ផ្ដើមជំនុំជម្រះលើសំណុំរឿង ០០២/០២ ដោយសារតែសំណុំរឿងនេះមានបញ្ចូលអង្គហេតុស្ដីពីសហករណ៍ត្រាំកក់។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនបានស្នើសុំទេ រហូតមកដល់ខែ មីនា ឆ្នាំ ២០១៥ នេះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចថា សហមេធាវីនាំមុខមិនបានខិតខំស្វែងរកដោយសមស្របទេ និងថា សំណើនេះមិនត្រូវបានដាក់ទាន់ពេលវេលា"។

សូមដាក់ជូនសំណើនេះដោយក្តីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |